Le « crochet » pour piquer l'éléphant (planté à côté) (tɔːŋ krɛːw gɛj maː coːk rwɛh)



Les entraves (au cou de l'éléphant) (ŋleːŋ)
Des sandales (au cou de l'éléphant) (ɟɛːp nc$^{h}$ɔh)
Le fouet dans les mains de l'enfant assis sur l'éléphant (mɔŋ plaːj mat maː mhat)



Application de riz gluant sur la tête de l'éléphant (ḅuː lɜr mʔeːt taː ḅoːk rwɛh)





Le palanquin (wɜːŋ rwɛh (ḍuː mlɔm))

Onction avec du sang appliquée à l'aide d'une feuille de l'arbre-Brooc
(ḅuː mpɛh rwɛh maː mhaːm / ḅuː mpɛh maː nhaː cʰiː ḅrɔːc)



Les entraves (ɲle:ŋ)



Corde en peau de buffle utilisée pour la capture de l'éléphant (rc$^{h}$ɛ: ḅrat)



Déplacement à dos d'éléphant (ḅu: ncɔ: rwɛh) - Corde qui passe sous le cou (rc$^{h}$ɛ: kɔ:), corde qui passe sous le ventre (rc$^{h}$ɛ: k$^{h}$o:ŋ), corde qui passe sous la queue (rc$^{h}$ɛ: ciaŋ), tapis posé sous le palanquin (ḍu:r)

## VII. VIE RELIGIEUSE ET SACRIFICE

La vie religieuse tient chez les Bunoong, comme dans beaucoup de cultures, une place prépondérante. Les dieux, innombrables, sont présents partout, mais plus particulièrement dans les « forêts sacrées », souvent près des sources, des grands rochers ou des chutes d'eau. Ces endroits que les Bunoong divisent en **brii nga** et **brii kan** sont réputés dangereux si on ne respecte pas l'intégrité des lieux. Il est notamment interdit d'y chasser et d'y défricher pour ouvrir des essarts. Les dieux sont jaloux de leurs privilèges et des domaines qu'ils contrôlent. Ne pas respecter un interdit (**weer**) constitue une offense à l'égard des divinités dont l'autorité a été lésée. Il faut alors les apaiser par un sacrifice dont l'importance sera en proportion de l'offense commise. Les sacrifices peuvent grossièrement être classés en sacrifices expiatoires (**kuaaç**) et en sacrifices d'action de grâce (**kual/oop brah**). Les premiers sont offerts pour réparer un manquement à la tradition (inceste, naissance illégitime, désacralisation d'une tombe ou d'une forêt) ; les seconds pour rendre grâce et se concilier les divinités essentiellement lors des cycles saisonniers et des étapes de la culture du riz (semailles et récolte du riz, nouvel an…). Les sacrifices, outre leur fonction proprement religieuse, jouent un rôle très important dans la vie sociale. Le village entier y participe, les préparatifs, souvent considérables, sont faits en commun. Les chants et les discours entendus lors des grands sacrifices affirment l'unité du groupe et la solidarité de ses membres. La distribution de la viande et l'offrande d'une boulette de riz gluant aux participants renforce le sentiment d'appartenance à la communauté. Il en va de même pour les prières « à l'embouchure de la jarre » et le partage du vin de riz. Ci-dessous les explications de Nchööp à propos des fêtes religieuses. Le premier nous confirme l'omniprésence du sacré ; le second décrit l'un des sacrifices les plus importants et nous montre la solidarité villageoise à l'œuvre pour préparer cette cérémonie essentielle.

## VII-1. Relations avec les dieux[19]

Les situations énumérées ci-dessous sont à éviter dans les rapports avec les dieux sous peine de maladie. Les cas les plus courants sont les suivants : le fait de ne pas se conformer aux rites de la cérémonie du dieu du riz, le fait qu'une jeune fille soit enceinte sans avoir de mari, le fait de ne pas respecter la tradition lorsqu'on défriche un champ, à un endroit dont les divinités tutélaires sont violentes, le fait de faire de fausses promesses aux dieux.

Il y a un grand nombre de problèmes traditionnels que nous avons l'habitude de résoudre. Si nous ne le faisons pas, aussitôt se manifeste une maladie, cela peut aller jusqu'à la mort dans certains cas. Si la tradition veut qu'on fasse une cérémonie pour un dieu en offrant des jarres d'alcool et qu'on néglige de la faire, alors la maladie se manifeste. Toutes les cérémonies doivent être conformes à la tradition quelle que soit leur importance, que se soit le sacrifice d'un porc, d'un taureau ou d'un buffle. Le fait d'oublier de faire une cérémonie provoque la maladie. Le fait de ne pas se conformer à l'endroit où le sacrifice doit être offert provoque la maladie. Le fait de procéder à un rite avec trop peu de moyens, par exemple un poulet seulement, fait apparaître la maladie. Si une divinité exige un porc, si la cérémonie se fait traditionnellement avec un porc, il faut la faire en sacrifiant un porc, alors la maladie disparaîtra. Nous avons l'habitude d'invoquer les divinités ou de communiquer avec elles. Elles sont nombreuses et variées les situations où traditionnellement on invoque les dieux. Voilà comment cela se passe : le dieu concerné manifeste son déplaisir au-delà de son territoire ; le dieu du riz transmet sa colère au dieu de la montagne. Si l'on a recours au guérisseur pour examiner le malade avec le cristal, alors on va savoir : le dieu du riz et le dieu de la montagne sont en colère, on n'a pas fait les cérémonies qui leur sont dues. Le feu dévore les récoltes de riz, le dieu est très en colère ; le riz se répand dans l'eau ; le dieu est très en colère, il rend les hommes malades. Le dieu des Bunoong, célèbre dans tout le pays bunoong, du côté des montagnes, c'est Jaang. Les gens l'invoquent très fréquem-

[19] Voir Annexes, le récit bunoong 5. nti:l na:w nḍrap ɗah ḅrah, p.156, tiré de « Éléments de langue phnong », pp 187-189.

ment, depuis les temps anciens, partout en pays bunoong. Le premier parmi des dieux, son nom est Jaang, les gens tous ensemble l'invoquent très souvent...Les gens l'invoquent partout où l'on fait des cérémonies pour les dieux, tous les ans, toutes les saisons, si c'est l'occasion de faire une cérémonie aux dieux.
Ils marchent dans la forêt, ils cherchent le premier riz, le premier tabac, ils communiquent avec le dieu et lui demandent, à lui Jaang, le dieu des montagnes dont on connaît traditionnellement le nom. Ce dieu Jaang, c'est lui qui manifeste le pouvoir surnaturel le plus violent, si l'on se trompe lors d'une cérémonie, si l'on ne tient pas compte de ses ordres, nous autres, les hommes, tombons gravement malades.

## VII-2. Préparation aux ablutions et au bain du petit dieu, l'âme du riz[20]

Les objets qu'on a l'habitude de chercher et d'utiliser pour faire la cérémonie de l'âme du riz, nous les énumérons ci-dessous : on va chercher une bufflesse ou un buffle adulte, on va chercher une vache ou un taureau. Le maître de maison engage trois jeunes filles ; il engage trois jeunes gens aussi. Les filles vont fendre du bois pendant dix jours, elles feront quatre tas ; en même temps elles vont piler trois grandes hottes de riz. Les garçons vont couper les bambous **rlaa** pour fabriquer le poteau qui soutient le plateau **ndrööng** ; couper les bouts des bambous ; couper des arbres **rmuan** pour faire les décorations nommées **rbleep**. Ils vont chercher des feuilles de l'arbre **chhaa** pour les suspendre au poteau de bambou, couper des arbustes pour faire la palissade, pour se protéger du buffle ou du taureau... Ils vont chercher des troncs d'arbres **Blaang** pour attacher le taureau et le buffle. Ils coupent six de ces arbustes, trois piquets pour attacher le taureau, trois piquets pour attacher le buffle ; ils sont de la taille d'un avant bras, d'une longueur dépassant la taille d'un homme, pour y attacher la corde qu'on passe autour du cou du buffle. On coupe des bambous **glee** pour faire un lit, endroit où l'on s'assoira pour invoquer les dieux, devant la maison tout près de la porte. Ensuite, on coupe quatre tubes de bambou **rlaa** ; chaque bambou devra avoir six

[20] Voir Annexes, le récit bunoong 6. nḓrap tɔʔ um ḓaːk kɔːn ḅrah hueːŋ ḅaː, p.157, tiré de « Éléments de langue phnong », pp 171-175.

nœuds. On prend un petit morceau de bois, on l'enfonce dans le tube de bambou, on perce cinq nœuds pour n'en conserver qu'un seul tout en bas, on fait cela avec les quatre tubes de bambou. Ensuite on va chercher des troncs d'arbres pour les planter dans le sol et placer contre lui les tubes à eau, à côté d'eux. On coupe des bambous **glee** pour tresser les grils – dans lesquels on coincera les saucisses pour les griller. Lorsque tout est fini, lorsqu'on a terminé les préparatifs, ils vont prévenir toutes les familles dans le village, ils leur ordonnent de venir ; toutes les jeunes filles, les jeunes gens, les anciens, tous viennent à la maison du dieu. Ensuite, ils ordonnent aux jeunes garçons d'amener le taureau et le buffle qui étaient attachés au poteau de l'arbre **Blaang**. On prend un petit porc, une jarre d'alcool, on les pose près du poteau du buffle, près du poteau du taureau... On verse de l'eau près de la jarre à alcool, on y enfonce un tube, on lie le petit porc, on prend son sang, on invoque les dieux, près du poteau du taureau et du buffle. Ils demandent à l'âme du taureau et du buffle de prendre leur sang pour invoquer et supplier l'âme du riz, que l'âme du riz descende boire, descende manger. Cette nuit, ils boivent toute la nuit jusqu'à ce qu'il fasse jour ; le lendemain, lorsqu'il fait à peine clair, ils appellent les enfants, filles et garçons et distribuent les tâches. Ils vont chercher des jeunes garçons en supplément, en sorte qu'ils aient trois personnes de plus pour puiser l'eau et chercher de l'alcool dans la maison. Trois autres hommes tueront le taureau et le buffle, dehors, dans la cour, en bas. Pendant qu'on éventre les victimes, il y en a d'autres qui aident à les éventrer aussi ; c'est alors que sort l'ancien, le maître de maison, il distribue la viande et prépare la soupe rapidement pour que les hôtes mangent. Il choisit un bon morceau de viande rouge avec le foie et les poumons et ordonne aux jeunes garçons d'aller chercher les intestins du buffle. Ils les vident bien sans les percer, les nettoient pour qu'ils soient débarrassés des excréments, ils hachent la viande avec le foie pour les réduire en petits morceaux. Ensuite les femmes pilent les ingrédients pour bien les mélanger et elles y mettent du sel pour qu'il y ait un goût salé comme d'ordinaire. On presse les ingrédients pour qu'ils pénètrent la viande, on enfonce le tout dans l'intestin du buffle en sorte qu'il soit bien rempli jusqu'au bout, on coince la saucisse dans le gril et on la fait griller au dessus du feu. Ensuite les anciens ordonnent aux enfants de couper un bout de la queue du buffle ou de la queue

du taureau, on les enfonce sur le poteau où sont attachés le taureau et le buffle. On prend le sang du taureau, le sang du buffle, de l'alcool de la jarre de l'intérieur de la maison, et on invoque les dieux près des poteaux du taureau ou du buffle aussi. Ensuite on va chercher la tête du taureau ou la tête du buffle dans la maison, on les pose près de la jarre à alcool sur le sol, on se prépare à bouillir le foie du buffle, le foie du taureau, lorsqu'ils sont bien bouillis, on les coupe en petits morceaux et on les met dans des assiettes, on les porte sur le grenier à riz. On découpe des petits **njoh** et on les enfonce sur le riz, on prend une calebasse d'eau, ainsi que du riz gluant, on pompe cinq ou six bouteilles d'alcool, on prend une assiettée de riz, une bougie, on prend du sang de buffle, du sang de taureau, on porte les verres pour boire l'alcool là-haut. Alors on invoque les dieux dans le grenier à riz, tous les anciens boivent chacun un verre d'alcool, tous ceux qui sont montés là-haut. Ensuite on cherche une calebasse à eau, on en verse le contenu sur le riz, alors on crie «heu, heu, heu ». On va chercher le foie du buffle qu'on a fait bouillir à point, on se le donne les uns aux autres et on crie : «heu ! heu ! heu !». On boit tout l'alcool des bouteilles et on redescend à terre tous ensemble. Ensuite on prend le sang du taureau, du buffle, on le touille, on prend le sang du taureau et du buffle et on le met sur l'anse de la jarre. La tête du taureau doit correspondre à trois jarres, la tête du buffle correspond à trois jarres, en tout six jarres, on « sacrifie » (boit) trois jarres devant chaque tête. Ensuite on invoque le dieu du riz, près des jarres sur lesquelles on a mis du sang de taureau et du sang de buffle, sur les anses des jarres, on invoque le dieu du riz tous ensemble, pendant le temps de cuire la viande, une demi-heure.

Alors les jeunes filles et les jeunes gens boivent, ils boivent énormément, toute la nuit jusqu'à l'aube. À l'heure où le soleil est au plus haut (10 à 12 heures du matin), les enfants du maître de cérémonie coupent la saucisse en petits morceaux de deux doigts de longueur. Tous les enfants du maître de maison vont chercher la saucisse, vont chercher le riz gluant et le donnent à manger à leur père et à leur mère. Ils prient le dieu, ils demandent des mérites pour leur père et pour leur mère, que, lorsqu'ils cultivent leur champ, ils aient deux cents ou trois cents hottes de riz pour la récolte à venir. Ensuite, c'est la mère et le père qui offrent de la nourriture à leurs enfants à leur tour,

ils disent à leurs enfants : « Vous autres, jeunes frères, nos enfants, cultivez de grands champs, vous aurez du riz en quantité suffisante pour en vendre, pour l'échanger contre quelques vaches et quelques buffles, ne soyez pas paresseux, ayez honte de ce que diraient les gens. » Ensuite ils distribuent la saucisse à tout le monde, ils prennent encore une jarre d'alcool, font boire leur père et leur mère, ceux-ci boivent d'abord, ensuite leurs enfants. Alors on fait boire les jeunes filles et les jeunes gens tous ensemble, tous s'amusent dans la joie, se chamaillent et se réjouissent. On prend les cymbales et on fait de la musique, certains chantent en se répondant alternativement. À ce moment-là on distribue la viande à tout le monde dans tout le village, cette nuit, on boit toute la nuit, lorsque l'alcool est devenu fade, chacun rentre chez lui. Le lendemain matin, on prend une jarre d'alcool, on la donne aux enfants, filles et garçons, les enfants de ceux à qui on est allé les « emprunter ». On prend de la viande pour eux, on prend de l'alcool pour ces jeunes filles et ces jeunes gens ; ils boivent d'abord. Ensuite on leur donne des conseils de savoir vivre ; lorsque l'alcool est devenu fade, ils retournent chez eux.



Mise à mort du buffle avec la hache (co:k rpu: ma: c$^{h}$u:ŋ)



Sacrifier aux morts, faire un sacrifice pour avoir désacralisé une tombe. (**ɟa:n b̤rah p$^{h}$a:n, kua:ç mo:c b̤la:ŋ**[21])



Prière devant le mât décoré de **ɲɟoh** (sacrifice à l'âme du riz) (**rac b̤rah ta: ngɔŋ ɲɟoh b̤a:**)



Prière à l'embouchure de la jarre (sacrifice expiatoire) **rac (b̤rah ta: b̤ɔr jaŋ)**

[21] Mot à mot : faire cérémonie dieux trépassés faire sacrifice cimetière (cercueil en bois blaang)



Le sacrifiant offre une poignée de riz gluant aux participants (təmc$^h$iam mʔe:t)



Offrande de haricots mélangés à du riz gluant (təmc$^h$iam wa:ɲ la:j mʔe:t)



Offrande de haricots mélangés à du riz gluant (təmcʰiam waːɲ laːj mʔeːt)



Scènes du sacrifice à l'âme du riz (ɟaːn hueːŋ ḅaː)





Poteau du sacrifice (ngɔŋ ɟaːn b̤rah)



Décorations rituelles pour un petit sacrifice
(nd̤raːk b̤aː  oːp b̤rah ɟeʔ)



mpɔːp et brochettes de viande (mpɔːp, puac mpam)



Statuettes représentant des humains et des nuːn
(kɔːn nuːç  kɔːn nuːn)



cf. croquis H14 (ngɔŋ klɜːk)





La tête de l'être (divin) (ḅoːk ḅuː)[22]

[22] ḅuː ɟaːn ḅoːk ḅuː iː nɛj gɛj maː kʰɜt rlɔk nciar kʰɛj pʰaːm rnoːk ḅaː hoːm ɛː ɟeʔ ɟeʔ ḅuː ɟaːn maː iar nhaːɲ nḍraɲ jaŋ ɟeʔ ḅuː kual lah craːç ḅaː « Cette effigie est faite pour tuer les parasites, les vers rlɔk et les termites au mois d'août, lorsque le riz est encore petit. On offre un poulet et une petite jarre d'alcool, ce sacrifice s'appelle craːç ḅaː ».



On enfonce un poteau avec des nḓra:k ḅa: pour un petit sacrifice (cut)



Sacrifice près d'un puits (ɟa:n ḅrah ta: nḍrɔm ḍa:k)[23]

[23] ḅu: ɟa:n ḅrah ta: nḍrɔm ḍa:k rno:k gɛh na:w ɟi: ḅu: nuç tɔm ɓɔ:n ɟa:n ma: nḍro:k mo: lah rpu: lah mo: ɟi: ḅu: ɟa:n ḍɜ:m gɛh ɗɔŋ an ḅrah nḍɔm ḍa:k ma: mɔt kɔ:n peʔ kɔ:n cʰɛ:
« On fait ce sacrifice lorsqu'il y a des malades dans le village, on offre un taureau ou un buffle. Il arrive aussi qu'on le fasse uniquement pour demander à la divinité de protéger et faire grandir les enfants du village ». « Est fait avec du bambou glɛ:. L'âme du riz s'y déplace et prend place sur le tum »

# VIII. CROQUIS

## A) cuaːɲ ɟɛj

| | |
|---|---|
| 1) ɓoːk cɔːr | 5) ngap |
| 2) cɔːr (ntaʔ ɟaː) | 6) mpoːŋ |
| 3) mɓuŋ (ɟaː) | 7) mpiːr |
| 4) mpaɲ | 8) ɟɔŋ guːŋ |



**B) ɟaːn ɟɛj**

| | | | |
|---|---|---|---|
| 1) cʰeːk ɟaː | 4) ngap (pʰah glɛː) | 7) mɛh | 10) mpiːr |
| 2) ɟaː ḍṳː peat | 5) ɲuaɲ | 8) ngap | 11) ngɔŋ |
| 3) rnaɲ nkaːr | 6) ciaŋ ɟaː | 9) mpaɲ | 12) rnaːɲ |



**C) ɟaːn ɟɛj**

1) mɛh
2) rgɜl
3) nɟɔːm ntur baː
4) loːk troːm
5) $rc^h$ɛː rɛh



**D) ɟɔŋ cʰur nak cʰaː**

1) ɟɔŋ cʰur
2) mɔŋ ɟɔŋ cʰur
3) mɔŋ mprɔːp ɟɔŋ cʰur
4) rcʰɛː wan
5) mɔŋ nd̤rɔː braːj / mɔŋ rnaːɲ kloːŋ braːj
6) wɛːl
7) mpɛh taː
8) mɔŋ cɛh
9) mɔŋ nkɔː
10) mɔŋ ɟɜːk
11) mɔŋ luːn mɔŋ uh mɔŋ cʰrɛː
12) braːj rnɜŋ
13) mɜŋ trɜm
14) ɟɔŋ trɜm



**E) k$^h$ɔŋ ruːj braːj**

1) ngɔŋ
2) druŋ
3) ntaːr
4) glɔː / tɔːŋ rnuːŋ
6) rc$^h$ɛː poːç / rc$^h$ɛː ruːc
7) dɜm k$^h$ɔŋ
8) plaːj mat draŋ
9) draŋ / mɔŋ draŋ
10) ḅoːk gɜːp (jɜːp)
11) toːr ɛːŋ
12) braːj ŋloːn
13) dɛːt k$^h$ɔŋ
14) ɟɔŋ
15) mliː



**F) wɜːŋ rwɛh**

1) mɛː wɜːŋ
2) kɔːn wɜŋ
3) ngɔŋ
4) ntaːr
5) rcʰɛː kʰoːm
6) ḍɜm wɜːŋ







**G) ɟaːn ḅrah**

1) ngɔŋ
2) njɔh
3) mpɔːp
4) cʰrɜŋ
5) nɔːŋ iar
6) kʰuaːŋ nɔːŋ iar
7) njɔh rɓleːp
8) (tɜːm) blaːŋ
9) (tɜːm) nkaːr
10) cʰah
11) kɔːn nuç
12) nkɛː paʔ nkɛː ḍaːŋ
13) tɔːŋ nkaːr
14) ŋɔʔ pac
15) jaŋ

**H) ngɔŋ ɟaːn ḅrah**

1) ciaŋ (kaː) kur
2) kriːŋ
3) rcʰɛː braːj
4) nḍɔh pɜʔ
5) njɔh
6) ngɔŋ
7) mpɔːp
8) guːŋ
9) rcʰɛː ḅrat
10) ngɔŋ kʰɔːŋ kʰaːŋ
11) cʰiaːw pʰɛː rmɜt
12) ngɔŋ nḍraːk
13) naːr klaːŋ
14) klɜːk
15) leːp
16) nḍraːk






**I) ɟaːn b̤rah**

1) ngɔŋ
2) ngɔŋ ncʰoːl
3) mɔŋ nʔaŋ
4) nɔːŋ iar
5) kʰuaːŋ
6) njɔh

**J) ɟaːn b̤rah**

1) moːŋ maːŋ
2) naːr klaːŋ
3) mɔŋ joːŋ klɜːk
4) klɜːk
5) leːp






**K) boːk ḅuː**

1) teːp
2) ngɔŋ
3) ḅeːŋ
4) loːŋ

## VIII-1. Commentaires et explications

**G-3,H-7)** mpɔːp b̤uː ɟaːn ruːp nɔːŋ iar teʔ puac iar mʔeːt nuaɲ maː cʰrɜŋ puac mpɔːp cʰrɜŋ toːr ciaŋ rpuː moː lah nd̤roːk klɜːm klɜːm cʰɔh plaːj nuːç b̤uː teʔ b̤uː teʔ cʰrɜŋ iː nɛj maː mpɔːp an hueːŋ b̤aː maː cʰaː ciaŋ toːr klɜːm cʰɔh b̤uː joːŋ gɛj maː ɟun an iː meʔ mb̤ɜʔ hueːŋ b̤aː :
On fait le mpɔːp à l'image d'une cage à poule, on y pose des morceaux de poulet du riz gluant, une cordelette avec des brochettes de viande. Ces brochettes comprennent les morceaux d'oreilles, la queue du taureau ou du buffle, ainsi que des morceaux du foie, des poumons et du cœur. On les met sur le mpɔːp pour que l'âme du riz puisse manger, la queue, les oreilles, et les poumons, on les suspend là pour les offrir à la mère et au père de l'âme du riz.

**H-8)** guːŋ haːw, hueːŋ b̤aː haːw kalɜː tum : l'escalier par où monte et descend l'âme du riz. On le fait avec du bambou pour que l'âme du riz puisse monter et s'asseoir ;

**H-8)** tum : ntuk hueːŋ b̤aː guʔ mpɔːp nɔːŋ iar kʰuaːŋ guːŋ lɛʔ rŋɔːc ɟeːŋ tum : tum : ce sont les endroits où l'âme du riz prend place, il consiste dans les pièces suivantes : le mpɔːp, le nɔːŋ iar, le kʰaːŋ guːŋ

**H-16)** nd̤raːk b̤aː : lɛʔ rŋɔːc leːp naːr klaːŋ kual lah nd̤raːk b̤aː : le leːp et le naːr klaːŋ sont appelés nd̤raːk b̤aː.

**H-12)** ngɔŋ nd̤raːk : ɟaːn maː glɛː gɛh nd̤ɜː pram ntiːl nd̤raːk rwak naːr klaːŋ rpuː b̤ɛː klɜːk : c'est un poteau de bambou glɛː avec les parties suivantes : nd̤raːk rwak naːr klaːŋ (aile de l'épervier), rpuː (statuette de) buffle b̤ɛː (statuette de) chèvres et le klɜːk

**G-5)** kʰuaːŋ nɔːŋ iar : gɛj maː gɛh ruːp uɛh maː uiɲ : c'est un objet décoratif.

**G-11)** kɔːn nuç : kal ɛː ḅuː mḅɜːj cʰaɜ ḅuː nuç iːaɜ ḏɜŋ gɛh ḅuː kɜːt ɟaːn ḅuː kual kɔːn nuç kɔːn nuːn : auparavant, on a fait des rêves, on y a vu ces humains, on fait des statuettes pour les représenter, on les appelle kɔːn nuç kɔːn nuːn

**G-12)** nkɛː paʔ nkɛː ḏaːŋ : ḅuː ɟaːn rnoːk ɟaːn ḅrah ḅaː cʰrɛh nḏroːk moː lah rpuː : on les fait lors du sacrifice d'un taureau ou d'un buffle.

**G-14)** ɲɔʔ pac ḏɜŋ tuːŋ nkɛː praː gɛj maː tɔʔ ḏaːk nḏraɲ ɲeːt : on s'en sert pour verser à boire et boire.

**G-13)** tɔːŋ nkaːr gɛj maː ɲeːt nḏraɲ : 10) tɔːŋ nkaːr : tube de bambou, on s'en sert pour boire.

**G-11)** tɔːŋ juːr gɛj maː juːr nḏraɲ ḅuː cʰɔʔ tɔːŋ juːr an maː troːm rcɔk gɛj maː təmpaʔ maː ḅuː : Le tɔːŋ juːr est un tube à transvaser, on s'en sert pour transvaser l'alcool dans une bouteille pour le partager entre les participants.

# អារម្ភកថា

នៅឆ្នាំ២០០១ អង្គការយូណេស្កូបានអនុម័តលើសេចក្តីប្រកាសជាសាកលរបស់អង្គការយូណេស្កូស្តីអំពីនានាភាពវប្បធម៌។ ការធ្វើសេចក្តីប្រកាសនេះគឺជាការបោះជំហានមួយដ៏ធំទៅមុខ ពីព្រោះថា នោះជាលើកទីមួយហើយដែលសហគមន៍អន្តរជាតិបានសម្តែងអោយឃើញនូវការជឿជាក់របស់ខ្លួនថា ការប្រាស្រ័យទាក់ទងអន្តរវប្បធម៌ ការគោរពចំពោះនានាភាពនៃវប្បធម៌ និងការអត់ឱនអោយគ្នាទៅវិញទៅមក គឺជាការធានាអោយមានសន្តិភាពដ៏ល្អមួយ។ សេចក្តីប្រកាសនេះផ្តល់នូវក្របខ័ណ្ឌមួយនៃគំរូសីលធម៌សាកលដែលមានគោលការណ៍ធានានូវសេចក្តីថ្លៃថ្នូរស្មើភាពគ្នារវាងវប្បធម៌ទាំងអស់ក្នុងលោក និងសំដៅទៅផ្តល់គំនិតដល់គោលនយោបាយវប្បធម៌។

ដោយមានការលើកទឹកចិត្តពីសេចក្តីប្រកាសនេះ និងដោយមានជំនឿយ៉ាងមុតមាំថា ការគិតគូរដល់ភាពជាក់ស្តែងនៃសង្គមនិងសេដ្ឋកិច្ច ត្រូវតែស្ថិតនៅក្នុងលំដាប់ជួរមុខនៃរាល់កិច្ចការងារប្រកបដោយចិរភាពទាំងឡាយនោះ គម្រោងរួមរបស់អង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ពោលគឺ កម្មវិធីទ្រទ្រង់ឧស្សាហកម្មច្នៃប្រឌិត ដែលផ្តល់ហិរញ្ញប្បទានដោយមូលនិធិប្រទេសអេស្ប៉ាញ តាមរយៈអង្គការសហប្រជាជាតិ ដើម្បីឈានទៅសម្រេចគោលដៅអភិវឌ្ឍសហស្សវត្ស បានគាំទ្រដល់ការបោះពុម្ពនូវស្នាដៃមួយចំនួនពាក់ព័ន្ធនឹងការស្រាវជ្រាវអំពីជនជាតិដើមនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយមានការសហការជាមួយអ្នកជំនាញល្បីៗដូចជាលោក ស៊ីលវ៉ាំង ហ្វូហ៊ិល ជាដើម។

ស្នាដៃដែលលោកអ្នកកំពុងកាន់នៅក្នុងដៃនេះត្រូវបានចងក្រងឡើងជាពីរភាសា គឺភាសាខ្មែរ និង ភាសាបារាំង បង្ហាញអោយឃើញនូវប្រព័ន្ធវប្បធម៌មួយដែលផ្អែកលើភាសា ការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយនិរន្តរភាព ជំនឿអរូបីគ្រប់ពេលវេលា និងបង្ហាញពីទស្សនវិស័យម្យ៉ាងលើពិភពលោក។

អ្នកនិពន្ធដែលមានជំនាញឯកផ្នែកភាសាព្នងនាពេលនេះ មិនញញើតនឹងទៅរស់នៅក្រោមដំបូលតែមួយជាមួយគ្រួសារជនជាតិព្នងឡើយ ដែលបច្ចុប្បន្នមិនមានជីវិតត្រាច់ចរដូចពីបុរាណទៀតឡើយ ដើម្បីប្រមែប្រមូលយក

ព័ត៌មានសំខាន់ៗមកចងក្រងជាស្នាដៃនេះឡើង ដែលជាផ្លែផ្កានៃការស្រាវជ្រាវអស់រយៈពេលដប់ប្រាំឆ្នាំមកហើយ លើវប្បធម៌និងអក្សរសិល្ប៍ជនជាតិព្នង។

ក្នុងនាមជាសាក្សីមួយរូបដែលបានមើលឃើញនូវដំណើរនៃការផ្លាស់ប្តូរសង្គមជនជាតិព្នងក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ លោក ស៊ីលវ៉ាំង ហ្វូហ៊្កិល ពិពណ៌នានៅក្នុងស្នាដៃនេះ អំពីការរស់នៅរបស់ប្រជាជនមួយនៅភាគឦសានកម្ពុជាដែលមិនទាន់សូវមានការសិក្សាអំពីកម្ពុជាណានិយាយដល់ឡើយ។ ដោយពិពណ៌នាអោយដឹងអំពីជនជាតិព្នង លោក ហ្វូហ៊្កិល ផ្តល់ជូនមិត្តអ្នកអាននូវគន្លឹះខ្លះៗសម្រាប់ជាការស្វែងយល់អំពីសង្គមរបស់ជនជាតិព្នងដែលកំពុងឈានទៅរកការបាត់បង់ ប៉ុន្តែជាសង្គមមួយដែលបញ្ជាក់ពីភាពសំបូរបែបនៃវប្បធម៌របស់ប្រទេសកម្ពុជា។ ការធ្វើដំណើរនៅក្នុងពិភពដ៏វិសេសមួយនេះគឺជាបុព្វសិទ្ធិដ៏កម្រមួយ ពោលគឺជាការខិតទៅរកមុខមាត់ដែលគេមិនដែលស្គាល់អំពីនានាភាពនៃមនុស្ស។ ពិធីសែនព្រេនបុរាណរបស់ជនជាតិព្នង របស់របរប្រើប្រាស់ក្នុងពិធីនានា របស់របរប្រើប្រាស់ប្រចាំថ្ងៃ កម្រងកំណាព្យកាព្យឃ្លោង និងប្រព័ន្ធចំណេះដឹងរបស់ពួកគេ ដែលកើតចេញពីអន្តរកម្មដ៏យូរលង់ជាមួយធម្មជាតិ ត្រូវបានកត់ត្រាជាឯកសារសំណេរតាមរយៈពាក្យពេចន៍របស់ជនជាតិព្នងដោយផ្ទាល់ និងត្រូវបានរៀបរាប់ឡើងវិញនាពេលនេះដោយលោក ស៊ីលវ៉ាំង ហ្វូហ៊្កិល។
ខណៈដែលតំបន់មណ្ឌលគិរីកំពុងទទួលរងនូវការប្រែប្រួលមិនអាចត្រឡប់ក្រោយបាន យើងខ្ញុំសង្ឃឹមថាស្នាដៃនៃការស្រាវជ្រាវ រំលេចទៅដោយរូបភាពនេះ នឹងអនុញ្ញាតអោយមានការអភិរក្សស្លាកស្នាមនៃវប្បធម៌មួយដែលកំពុងស្ថិតនៅក្នុងសភាពគ្រោះថ្នាក់ ក្នុងសម្មតិកម្មមួយដ៏គួរអោយសោកស្តាយ ប៉ុន្តែជាសម្មតិកម្មមួយជាក់ស្តែងនៃការបាត់បង់វប្បធម៌នេះ។

**អាន ឡឺម៉ែត្រ**
**តំណាងអង្គការយូណេស្កូប្រចាំកម្ពុជា**

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំសូមថ្លែងអំណរគុណដល់លោក Philippe Delanghe ប្រធានផ្នែកវប្បធម៌នៃការិយាល័យអង្គការយូណេស្កូនៅទីក្រុងភ្នំពេញ និងលោក Blaise Kilian អ្នកសម្របសម្រួលកម្មវិធីរួមនៃសហប្រជាជាតិតាមរយៈមូលនិធិអភិវឌ្ឍសហស្សវត្ស (កម្មវិធីគាំទ្រឧស្សាហកម្មច្នៃប្រឌិត)។ លោកទាំងពីរបានផ្តល់កិត្តិយស និងសេចក្តីទុកចិត្តដល់ខ្ញុំ អោយខ្ញុំតាក់តែងស្នាដៃនេះឡើង។ សូមអរគុណលោក Philippe Monin ដែលបានផ្តល់ការគាំទ្រនិងជួយផ្នែកភស្តុភារដែលជួយសម្រួលដល់ការធ្វើអង្កេតរបស់ខ្ញុំយ៉ាងខ្លាំង។ លោក Jean Philippe Layoyette ដែលជាជាតិពន្ធុវិទូស្គាល់មណ្ឌលគិរីច្បាស់ លោកបានផ្តល់ចំណេះដឹងនិងទំនាក់ទំនងរបស់លោកជាមួយជនជាតិព្នងជាប្រយោជន៍យ៉ាងច្រើនដល់ខ្ញុំ។ លោក Pierre Beausoleil ដែលបានធ្វើជាមគ្គុទ្ទេសក៍របស់ខ្ញុំនៅតំបន់ប៊ូស្រា សូមអរគុណសហការីរបស់ខ្ញុំ គឺលោក Joe Garrison ចំពោះការពិភាក្សារបស់លោកជាមួយខ្ញុំ ការយោគយល់និងពេលវេលាដែលលោកតែងតែផ្តល់អោយខ្ញុំ។ សូមអរគុណលោកស្រី Mireille Blot-Arsac និងលោក Mathieu Guérin ដែលបានជួយអាននិងកែលម្អអត្ថបទនេះឡើងវិញ។ ចុងក្រោយប៉ុន្តែក៏សំខាន់ដែរ ខ្ញុំសូមសំដែងការដឹងគុណចំពោះមិត្តភ័ក្តិដែលជាសហការីរបស់ខ្ញុំជនជាតិព្នង ដូចជាលោក ម៉ាល ផែន លោក ម៉ាល គឹម លោក ផ្លែន ថេ លោក ណោះ ដេហុក លោក គ្រឿន និងលោក កូវ សុវណ្ណ ដែលបានផ្តល់ព័ត៌មានសំខាន់ៗដល់ខ្ញុំ ឬលោកតា ឈើច ដែលស្គាល់ឈ្មោះព្រៃសក្ការៈទាំងអស់នៅប៊ូស្រា ឬក៏លោក ឆូវ ញ៉ែល និងអ្នកដទៃទៀត ដែលបានទទួលស្វាគមន៍ខ្ញុំ អោយខ្ញុំចូលរួមក្នុងពិធីផ្សេងៗដែលពួកគាត់រៀបចំឡើង និងក្នុងពិធីសែនព្រេននានា។

# ទិដ្ឋភាពនៃវប្បធម៌ប្រពៃណីរបស់ជនជាតិព្នង[១] នៅមណ្ឌលគិរី

[១] ពាក្យព្នង បើគេហៅអ្នកណាម្នាក់ថាជាព្នង គឺមានន័យមិនល្អឡើយ ប៉ុន្តែក្នុងស្នាដៃនេះ ពាក្យ ព្នង ក្នុងន័យទូលាយ សំដៅទៅក្រុមប្រជាជនដែលមកតាំងទីដំបូងនៅកម្ពុជា ក្នុងន័យចង្អៀត គឺសំដៅទៅជនជាតិភាគតិចនៅខេត្តមណ្ឌលគិរី។

# ប្រវត្តិ

ខ្ញុំបានធ្វើការសិក្សាស្រាវជ្រាវអស់រយៈពេលជាងដប់ប្រាំឆ្នាំមកហើយលើភាសានិងអក្សរសិល្ប៍ជនជាតិព្នង ព្រមទាំងជាសាក្សីនៃការផ្លាស់ប្តូរនានាដែលប៉ះពាល់ដល់ជនជាតិព្នងក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។ ដោយមានជំនួយពីអង្គការយូណេស្កូ តាមរយៈកម្មវិធីគាំទ្រឧស្សាហកម្មច្នៃប្រឌិត* ខ្ញុំបានទៅមណ្ឌលគិរីជាច្រើនដង ដើម្បីបណ្តុះបណ្តាលអ្នកអង្កេតជនជាតិព្នង អោយចេះប្រមែប្រមូលព័ត៌មានអំពីអក្សរសិល្ប៍បុរាណរបស់ពួកគេ ថែមទាំងរៀបចំស្នាដៃមួយស្តីអំពីសម្ភារៈរបស់ប្រជាជនដែលមកតាំងទីដំបូងនៅក្នុងខេត្តនេះ។ ខ្ញុំបានចាប់ផ្តើមការងារនេះរួចទៅហើយនៅពេលដែលខ្ញុំបានជួបលោក Joe Garrison។ លោកជាជាងថតរូបជំនាញម្នាក់ដែលធ្វើការអោយក្រុមហ៊ុន SOCFIN-KCD នៅក្នុងតំបន់ប៊ូស្រា។ លោក Joe Garrison បានចាប់អារម្មណ៍ភ្លាមនៅពេលដែលខ្ញុំបានរៀបរាប់ប្រាប់លោកអំពីគោលបំណងរបស់ខ្ញុំ នោះគឺ ថតទិដ្ឋភាពប្រពៃណីរបស់ជីវិតជនជាតិព្នង ព្រមទាំងផ្តល់ជូនអ្នកអាននូវការពន្យល់និងសេចក្តីអត្ថាធិប្បាយដែលមានប្រភពមកពីជនជាតិព្នងផ្ទាល់។ លោក Philippe Monnin ដែលកាលនោះជាអគ្គនាយកក្រុមហ៊ុន SOCFIN-KCD ក៏បានយល់ព្រមអនុញ្ញាតអោយលោក Joe Garrison ធ្វើការលើគម្រោងរបស់ខ្ញុំ ក្នុងក្របខ័ណ្ឌនៃការងាររបស់លោកដើម្បីក្រុមហ៊ុន និងបានជួយខ្ញុំផ្នែកភស្តុភារដែលចាំបាច់នានា។

* នេះជាគម្រោងដែលទទួលបានការឧបត្ថម្ភថវិកាពីមូលនិធិប្រទេសអេស្ប៉ាញ តាមរយៈអង្គការសហប្រជាជាតិ ដើម្បីឈានទៅសម្រេចគោលដៅអភិវឌ្ឍន៍សហស្សវត្ស និងដែលហៅកាត់ជាភាសាអង់គ្លេសថា MDG-F ។ កម្មវិធីទ្រទ្រង់ឧស្សាហកម្មច្នៃប្រឌិត ត្រូវបានអនុវត្តរួមគ្នាដោយអង្គការ UNESCO អង្គការ FAO អង្គការ ILO និងអង្គការ UNDP ដោយសហការយ៉ាងជិតស្និទ្ធជាមួយរាជរដ្ឋាភិបាលកម្ពុជា។

# ការបង្ហាញ

ស្នាដៃនេះមិនមានមហិច្ឆតាផ្តល់ជូននូវចក្ខុវិស័យរួម និងចក្ខុវិស័យមិនលំអៀង ស្តីអំពីជីវិតជនជាតិព្នង នាដើមសតវត្សទី២១នោះទេ ហើយក៏មិនមានមហិច្ឆតាធ្វើជាសាក្សីដ៏សុក្រឹតបំផុតនៃការវិវត្តន៍ដែលកំពុងប្រព្រឹត្តិទៅនោះដែរ។ ប៉ុន្តែជាការពិត រាល់សកម្មភាពដែលមាននៅក្នុងរូបថត ជាអាទិ៍ មានដូចជា ពិធីកាប់ក្របីបូជា ព្រមទាំងវត្ថុនិងសម្ភារៈដែលមានបង្ហាញជូនក្នុងរូបថត គេនៅតែឃើញមាននៅក្នុងជីវិតប្រចាំថ្ងៃរបស់ជនជាតិព្នងសព្វថ្ងៃនេះ។ ប៉ុន្តែ យើងបានសង្កត់ធ្ងន់ទៅលើទិដ្ឋភាពប្រពៃណីទំនៀមទម្លាប់ ខ្លាំងជាងទិដ្ឋភាពសម័យទំនើប។ មិត្តអ្នកអានគួរដឹងថានៅមណ្ឌលគិរីបច្ចុប្បន្ននេះ មានផ្ទះឈើ ឬផ្ទះថ្ម ច្រើនជាងខ្ទមស្លឹកបុរាណ មានម៉ូតូច្រើនជាងដំរី ហើយគេក៏ឃើញមានវិហារកាតូលិក និងវត្តអារាមផងដែរ។ ទាំងអស់នេះ ឬអាចថាស្ទើរតែទាំងអស់នេះ មិនមាននិយាយនៅក្នុងស្នាដៃនេះទេ ព្រោះថានេះជាស្នាដៃនិងជាការចងក្រងឯកសារដែលនិយាយតែអំពីប្រពៃណីមួយកំពុងឈានទៅរកការបាត់បង់យ៉ាងឆាប់រហ័ស និងបាត់បង់ជារៀងរហូតតែប៉ុណ្ណោះ។

យើងទើបបានពន្យល់រួចហើយ យើងអះអាងថារូបថតដែលមាននៅក្នុងស្នាដៃនេះ សុទ្ធតែបង្ហាញអំពីទិដ្ឋភាពប្រពៃណីទំនៀមទម្លាប់ ចំណែកឯសេចក្តីអត្ថាធិប្បាយក៏ដូច្នោះដែរ។ យើងមិនមានបំណងធ្វើការវិភាគមិនលំអៀងដោយសង្កត់ធ្ងន់លើអំណះអំណាងសង្គមនិងនយោបាយនោះទេ (សមាហរណកម្មជនជាតិដើមមួយទៅក្នុងរចនាសម្ព័ន្ធរដ្ឋមួយ) ឬ អំណះអំណាងសេដ្ឋកិច្ច (សមាហរណកម្មការប្រកបរបរចិញ្ចឹមជីវិតបែបបុរាណទៅក្នុងសេដ្ឋកិច្ចរួមមួយ) ប៉ុន្តែយើងចង់បង្ហាញជូននូវទស្សនៈរបស់ជនជាតិព្នងផ្ទាល់ ពោលគឺទស្សនៈដែលនិយាយចេញពីមាត់របស់ចាស់ៗជនជាតិព្នង ហើយដែលមានបង្ហាញជូននៅក្នុងកំណាព្យប្រពៃណី។ អត្ថបទព្នងដកស្រង់ចេញមកពីការពន្យល់របស់ លោកតា ណឹឈើប[២] ស្តីអំពីប្រធានបទជាច្រើន ដែលយើងលើកយកមកបង្ហាញជូននៅក្នុងសៀវភៅមានចំណងជើងថា "Introduction à la langue et aux dits des Phnong de Mondulkiri" (អំពីភាសា និងសំនួនវោហារបុរាណព្នងនៅមណ្ឌលគិរី) និងនៅក្នុងសៀវភៅដែលមានចំណងជើងថា "Éléments de langue Phnong" (លក្ខណៈភាសាព្នង) ព្រមទាំងនៅក្នុងកំណាព្យប្រពៃណីដែលមិនទាន់បោះពុម្ពផ្សព្វផ្សាយផងដែរ។

[២] លោកតា ណឹឈើប ហៅ កាំង លី ជាគ្រូរបស់ខ្ញុំរយៈពេលជាង១០ឆ្នាំ ផ្នែកភាសាព្នង និងវប្បធម៌ព្នង។ អត្ថបទ និងការពន្យល់នៅក្នុងសៀវភៅ «Éléments de langue phnong»បានព័ត៌មានមកពីគាត់ទាំងអស់។

សៀវភៅទីមួយពិពណ៌នាលំអិតអំពីការរៀបចំនិងការប្រព្រឹត្តទៅនៃពិធីនានា ហើយរូបថតបង្ហាញអំពីសកម្មភាពក្នុងពេលណាមួយនៃពិធីនោះ។ សៀវភៅទីពីររៀបរាប់អំពីអត្ថន័យរបស់របរប្រពៃណីមួយចំនួន មានដូចជា គង និង ឃ្មោះ នៅក្នុងជីវិតរបស់ជនជាតិព្នង។

មកដល់ចំណុចនេះ មិត្តអ្នកអានប្រហែលជាយល់ហើយថា ការបង្ហាញរូបភាពអមទៅដោយអត្ថបទ ស្នាដៃនេះនឹងសាកល្បងធ្វើអោយមិត្តអ្នកអានយល់អំពីប្រពៃណី[៣] របស់ជនជាតិព្នងនៅមណ្ឌលគិរី។

[៣] ពាក្យ ប្រពៃណី ត្រូវបានប្រើច្រើននៅក្នុងសៀវភៅនេះ ហើយគួរមានការពន្យល់ខ្លះ។ ក្នុងភាសាព្នង ពាក្យ ប្រពៃណី គេនិយាយថា waj bṳ: bṳɲ bṳ: ra:ɲ មានន័យថា ទម្លាប់ចាស់។ na:w kal ɜ:m មានន័យថា ប្រវត្តិមុនៗ។ ពាក្យទីមួយសំដៅទៅទម្លាប់ដែលបន្សល់ពីបុរាណកាលមក ហើយដែលគេស្គាល់នៅលើទឹកដីព្នងគ្រប់កន្លែង។ ពាក្យទីពីរសំដៅទៅ ទម្លាប់មុនៗ តាមពិតគឺទម្លាប់ដែលមានមុនឆ្នាំ១៩៣០ ពេលជនជាតិព្នងនៅមានឯករាជ្យផ្នែកនយោបាយ ច្បាប់ និង សេដ្ឋកិច្ចនៅឡើយ (ពុំទាន់មានអាជ្ញាធរកណ្តាល)។ ចំពោះរឿងទំនាក់ទំនងរបស់ជនជាតិព្នងជាមួយអាជ្ញាធរអាណានិគម ឬអាជ្ញាធរកណ្តាល សូមអានសៀវភៅ និងអត្ថបទរបស់លោក Mathieu Guérin ដែលបានលើកឡើងនៅក្នុងគន្ថនិទ្ទេស។

## ១. ភូមិបុរាណ

ភូមិ (bboon) ដែលមានផ្ទះទាបជាប់ដី (jey) និងផ្ទះវែងជាប់ដី (root) ប្រមូលផ្តុំទៅដោយមនុស្សចំនួនប្រមាណជាជាង២០គ្រួសារ គឺជាអង្គភាពនយោបាយនិងជាមូលដ្ឋានសង្គមរបស់ជនជាតិព្នង។ កាលពីជំនាន់ដើម ភូមិមានរបងឈើព័ទ្ធជុំវិញ ដើម្បីការពារសត្វសាហាវ ឬសត្រូវមកពីខាងក្រៅ។ ភូមិត្រូវបានដឹកនាំគ្រប់គ្រងដោយមនុស្សធំៗ ដូចជាមេភូមិ (koo raanh) ហើយភូមិនោះមានដែនដី (brii neh) និងព្រំប្រទល់ច្បាស់លាស់ (nhaar)។ នៅក្នុងព្រំប្រទល់ទាំងនេះ អ្នកភូមិអាច "ស៊ីព្រៃ" (chhaa brii) មានន័យថា កាប់ឆ្ការ រកជ័រ រកឃ្មុំ បរបាញ់សត្វ និងរកត្រីជាដើម។ ការធ្វើសកម្មភាពទាំងនេះក្រៅពីទឹកដីភូមិរបស់ខ្លួន គឺជាកំហុសផ្ទុយពីទម្លាប់ (naaw tih) ដែលត្រូវកែកំហុសឡើងវិញ។ ភូមិទាំងឡាយដែលប្រជាជនបោះបង់ចោលរយៈពេលប្រមាណជាង២០ឆ្នាំ បានក្លាយជា rhaang ឬ rngool (ភូមិចាស់) គេក៏ត្រឡប់មករស់នៅក្នុងភូមិចាស់ៗទាំងនេះវិញរយៈពេលបួនឬប្រាំឆ្នាំក្រោយ ដើម្បីប្រមូលភោគផលរុក្ខជាតិដែលគេដាំនៅក្នុងភូមិទាំងនោះមុននឹងពួកគេចាកចេញទៅ។ ការដែលរដ្ឋប្រមូលផ្តុំអោយប្រជាជនរស់នៅមានរបៀបនៅតាមបណ្តោយផ្លូវថ្នល់ដើម្បីធ្វើឲ្យពួកគេនៅនឹងមួយកន្លែង ព្រមទាំងសម្ភារៈប្រពៃណីមានកាន់តែតិចទៅៗ ធ្វើឲ្យជនជាតិព្នងកាន់តែបោះបង់ច្រើនឡើងៗនូវខ្ទមទាបរបស់ខ្លួនដែលសាងសង់នៅផ្ទាល់ដី មានជញ្ជាំងឫស្សី ដំបូលប្រក់ស្បូវ jaa ត្រឡប់ទៅសាងសង់ផ្ទះឈើពេលខ្លះមានទាំងផ្ទះថ្មទៀតផង។ ជនជាតិព្នងមានផ្ទះច្រើនប្រភេទ៖ chuaanh jey គឺជាពាក្យទូទៅ សំដៅទៅលើខ្ទមទាបជាប់ដី chuaanh nhih សំដៅទៅលើផ្ទះខ្ពស់មានសសរ chuaanh root គឺជាផ្ទះធំមានគ្រួសារច្រើនរស់នៅ roong សំដៅទៅលើផ្ទះបណ្តោះអាសន្នរបស់គ្រួសារមួយដែលរង់ចាំខ្ទមទាប (jey) សាងសង់រួច chuun សំដៅទៅលើខ្ទមសម្រាប់ស្ត្រីឆ្លងទន្លេ ហើយពាក្យ chuaanh nköөp សំដៅទៅលើខ្ទមដែលសង់ខ្ពស់លើចម្ការដើម្បីយាមដំណាំ។
អត្ថបទទាំងពីរដែលយើងបានលើកឡើង ផ្តល់ទស្សនៈពីរខុសៗគ្នារបស់ជនជាតិព្នង។

អត្ថបទទីមួយមានចំណងជើងថា "La maison d'un chef" (ផ្ទះមេកន្ទ្រាញ) ពិពណ៌នាអំពី jey ។ ជនជាតិព្នងដែលបានសង់ jey ជាច្រើនដោយខ្លួនឯង ហើយថែមទាំងបានរស់នៅក្នុងផ្ទះនោះដែរ បានធ្វើការពិពណ៌នាលំអិតអំពីផ្ទះរបស់គ្រួសារអ្នកមានមួយ។ ទំហំផ្ទះ សម្ភារៈក្នុងផ្ទះ ទីកន្លែងដាក់សម្ភារៈផ្សេងៗ ដូចជារបស់មាន

តម្លៃ (ndöö kley) ត្រូវបានពិពណ៌នាយ៉ាងច្បាស់លាស់បំផុត។
អត្ថបទទីពីរពិពណ៌នាអំពីភូមិមួយ។ វាជាអត្ថបទដែលដកស្រង់ចេញពីកំណាព្យបុរាណដ៏វែងមួយ (ndroong) ដែលគេបានចម្លងនិងបកប្រែប្រួន ប្រាំឆ្នាំមកហើយ។ យើងបានដាក់ចំណងជើងអត្ថបទនោះថា "Village de Chiang" (ភូមិជាំង)។ ភូមិជាំងគឺជាភូមិដ៏ល្អបំផុតដែលជនជាតិព្នងស្រមៃចង់បាន ពោលគឺជាភូមិស្អាតនិងសំបូរសប្បាយ។ នៅក្នុងរឿងព្រេងមួយរបស់ជនជាតិព្នង ប្រាង្គប្រាសាទអង្គរត្រូវបានគេនិទានថាជាប្រាសាទបាក់បែករបស់ភូមិជាំងបុរាណ ដែលត្រូវបានប្រជាជនទាំងនេះបោះបង់ចោល។ មិត្តអ្នកអានងាយនឹងឃើញភាពច្រំដែលនៃសូរ និងភាពច្រំដែលនៃព្យញ្ជនៈដែលជាទម្រង់មួយនៃកំណាព្យ។ តាមរយៈភាពល្អឥតខ្ចោះនៃកំណាព្យ មិត្តអ្នកអាននឹងយល់អំពីបរិស្ថាន និងបរិយាកាសនៃភូមិមួយដ៏ល្អឥតខ្ចោះ ដូចដែលកំណាព្យប្រពៃណីរៀបរាប់ឡើងដូច្នោះដែរ។ អត្ថបទទាំងនេះ ពិពណ៌នាអំពីភូមិជនជាតិព្នងដែលហួសសម័យទៅហើយក្នុងពេលបច្ចុប្បន្ននេះ។ បើទោះបីជាឃ្មោះ គង ពាងជាច្រើនប្រភេទ ព្រមទាំងសត្វពាហនៈ នៅមានក្នុងសង្គមព្នងសព្វថ្ងៃនេះក៏ដោយ ក៏ root ផ្ទះវែងជាប់ដីបានបាត់បង់ជាយូរយារណាស់មកហើយ រីឯ jey នៅពេលនេះក៏មានកាន់តែតិចទៅៗដែរ។

## ១.១. ផ្ទះរបស់ចាស់ទុំម្នាក់[៤] (koraanh)

មេភូមិរស់នៅកណ្តាលភូមិ។ ផ្ទះរបស់មេភូមិមានបណ្តោយពី៧ ទៅ១៥ហត្ថ។ សរុបទាំងអស់ប្រវែងស្មើនឹងស្បូវ jaa ពីប្រាំ ទៅដប់ដើម ឬប្រមាណពី១០ ទៅ២០ម៉ែត្រ។ ប្រជាជននៅក្នុងភូមិសង់ផ្ទះរបស់ខ្លួននៅពាសពេញភូមិជិតៗម្តុំ koraanh ផ្ទះមេភូមិ។ នៅក្នុងផ្ទះរបស់អ្នកមាន ពាងធំៗត្រូវបានចងភ្ជាប់នៅលើគ្រែដែលលាតសន្ធឹងពីជញ្ជាំងផ្ទះម្ខាងទៅជញ្ជាំងផ្ទះម្ខាងទៀត។ kuat និង njoh ត្រូវបានចងភ្ជាប់នឹងដំបូលខាងឆ្វេងគ្រែត្រង់បន្ទប់មេផ្ទះ។ ផ្នែកកណ្តាលគ្រែគឺជាកន្លែងសម្រាប់ភ្ញៀវដេក កន្លែងសម្រាប់ធ្វើការ និងកន្លែងបន់ព្រះ។ នៅលើដី ត្រង់កន្លែងដែលគេបង្កាត់ភ្លើង មានកៅអីធំមួយ។ នៅខាងលើមានធ្នើរដាក់អីវ៉ាន់គ្រប់ប្រភេទ៖ កាផា កាផាសម្រាប់ដាក់ឃ្លោក ទ្រូ កញ្ជើ ខ្សែគោ ខ្សែក្របី ផ្គាក់ ពូថៅ ខ្វែវ ចបជីក។ ជង្រុកស្រូវ គេដាក់នៅខាងលើ។ ខាងឆ្វេងជណ្តើរ គេដាក់កញ្ជើទុកស្រូវពូជ។ ជណ្តើរសម្រាប់ឡើងទៅយកស្រូវ គេដាក់ចំកណ្តាលផ្ទះ។ ជណ្តើរនេះ គេធ្វើឡើងដល់ជង្រុកស្រូវតែម្តង។ នៅលើគ្រែខាងស្តាំ មានបន្ទប់កូនស្រី ភ្ញៀវស្រីៗក៏តេងនៅលើគ្រែនេះដែរ ក្នុងបន្ទប់តែមួយ។ ធ្នើរសម្រាប់ដាក់ឃ្មោះនិងគង នៅជិតបន្ទប់ម្ចាស់ផ្ទះ។ ធ្នើរសម្រាប់ដាក់អង្ករនៅជិតបន្ទប់កូនស្រី។ កន្លែងដែលគេបង្កាត់ភ្លើងដាំស្ល នៅខាងក្រោមជង្រុកស្រូវ។ នៅខាងក្នុងបន្ទប់ គេដាក់ពាង rluung។ នៅជិត kuat មាន

[៤] ខ្លឹមសារដកស្រង់ចេញពីសៀវភៅដែលមានចំណងជើងថា «Éléments de langue phnong» ទំព័រ ១៤៣-១៥០ សូមមើលអត្ថបទព្នងនៅក្នុងឧបសម្ពន្ធ រឿងនិទាន ១. ɟej koːraːɲ ទំព័រ ១៥១

ឧបករណ៍ភ្លេងធំ តូច ធ្វើពីស្នែង mbuat, rleet និងខ្លុយ។ នៅខាងស្តាំ ជិតទ្វារចូល  គេដាក់ពាងទឹក។ នៅមុខផ្ទះ មានទីធ្លាសម្រាប់អង្គុយលេង។ នៅមុខទីធ្លានោះ មានរោងសម្រាប់ទុករយាង រទេះ ព្រមទាំងជាកន្លែងសម្រាប់បុក អង្ករនិងអង្គុយទៀតផង។ នៅកៀនផ្ទះ មានទ្រុងជ្រូក ទ្រុងមាន់ ទ្រុងពពែ និងទ្រុងទា។ នៅចម្ងាយប្រមាណជា ២០ម៉ែត្រពីផ្ទះ គេធ្វើក្រោលគោ និងក្រោលក្របី។ អណ្តូងនៅចម្ងាយប្រមាណជា៣០ជំហានពីភូមិ។

## ១.២. ភូមិ ជាំង[៥]

ដូច្នេះ ខ្ញុំនឹងនិទានប្រាប់មិត្តអ្នកអាននូវអ្វីដែលខ្ញុំបានឮគេនិយាយនៅភូមិជាំង... ពីកន្លែងផ្ទះវែងជាប់ដី...
ផ្ទះក្លឹង ជាផ្ទះមួយ Root ដែលគេសាងសង់បានល្អ សូមស្តាប់អោយច្បាស់៖
ផ្ទះវែងនៅខាងនោះ ជាផ្ទះ Koong និង Jaang
ផ្ទះធំ រាប រាងមូល ជារបស់ Nduu កូនប្រុសរបស់ Bung
នៅមាត់ព្រៃខាងនោះ មានសត្វគួរអោយខ្លាច...
ផ្ទះ Root របស់ប្អូនស្រី Brish រាងវែង ប្រវែងផ្តៅមួយដើម
ផ្ទះ Root របស់ប្អូនស្រី Bresh រាងវែង ប្រវែងផ្តៅមួយដើម
Chiang និង Taang មានផ្ទះវែងដូចខ្សែខ្លែង
Leeng និង Koong ក៏មានផ្ទះ Root វែងដែរ
ភូមិជាំងមានក្លិនពិសេស
មានក្លិនផ្កា Tup
មានក្លិនផ្កា Traang
ក្លិនច្រើនមកពីខាងខ្មែរ
ក្លិនច្រើនមានច្រើននៅខាង Biat
មានក្លិនផ្កា Piat នៅព្រៃខាងលើ
មានផ្ទះខ្ពស់ៗ មានចម្លាក់
ផ្ទះខ្ពស់របស់លោកម្ចាស់ Joong គេឆ្លាក់រូបមនុស្ស
ផ្ទះលោកម្ចាស់ Joong គេឆ្លាក់រូប Nuun
មានផ្ទះខ្ពស់ ដែលគេមើលឃើញអ្វីៗនៅឆ្ងាយឡឹមៗ ហើយមានដំបូលធ្វើពីផ្តៅ Kloot

[៥] អត្ថបទនេះមានបីផ្នែក ដកស្រង់ចេញពីកំណាព្យបុរាណ (ndroong) ដែលមិនទាន់បោះពុម្ព។ សូមអានអត្ថបទព្នងនៅក្នុងឧបសម្ពន្ធ រឿងនិទាន ២. 6ɔːn ciaŋ ទំព័រ១៥១

មានផ្ទះខ្ពស់ ដែលគេមើលឃើញអ្វីៗនៅឆ្ងាយឡឹមៗ ហើយមានដំបូលធ្វើពីផ្តៅ Drang
មានផ្ទះខ្ពស់ មាំ ទប់ខ្យល់បាន មានដំបូលស្រួច
ហេតុអ្វីក៏និយាយផ្ដេសផ្ដាស...
នៅខាងក្រៅ គេឮសំឡេងអឺងកង និងសំណើចក្អាកក្អាយ
បើគេមើលទៅចុងភូមិទាំងសងខាង គេឃើញកុមារា កុមារី គ្រប់កន្លែង
បើគេមើលក្នុងទ្រុង គេឃើញគោ Nhoong គ្រប់កន្លែង
បើគេមើលទៅចុងភូមិ គេឃើញទម្រង់មូលនៃហ្វូងពពែ។ ពពែស ពពែស្រមូម
កូនពពែ ពពែស
បើគេមើលចំកណ្ដាលភូមិ គេឃើញសេកធំៗនៅក្រោមផ្ទះ
គេឮសំឡេងសត្វសេកស្រែកអឺងកង គ្រប់កន្លែង នៅលើដើមឫស្សីដែលគេពុះហើយ។
មានជ្រូកជាច្រើននៅក្នុងភូមិជាំង កូនប្រុសរបស់ Rong ដូចកណ្ដៀរ
មានមាន់ជាច្រើនដូចស្រមោច
គេចងជើងដំរីដូចជាចងរូបដំរីដែលគេឆ្លាក់នៅក្នុងចម្ការចេកព្រៃ
គេមិនអាចទៅរួចទេ មានដំរីច្រើនពេក គេលែងវាចោលក្នុងព្រៃ
ក្របីច្រើនរហូតដល់ថ្លុកទឹកដែលវាដេកត្រាំស្រុតចុះជ្រៅ
ពាង Rluung ច្រើនរហូតដល់ត្រូវចងព្យួរក្នុងកន្ត្រក
ជ្រូកច្រើនដូចរូបចម្លាក់ធ្វើពីឈើខ្មៅ ហើយរឹង
ក្របី Ndam Dung នៅក្នុងភូមិជាំងមានបីវាល
ក្របី Ndam Dung មានបីក្រោលពេញដែលធ្វើអំពីឈើដើម Blaang
ក្របីឈ្មោលចាស់ៗ Dju និង Djaaw មានហុកសិបក្រោល
គេពាក់ត្រដោកធ្វើពីថ្មអោយក្របី
គេពាក់ត្រដោកធ្វើពីឈើរឹងអោយក្របី
ត្រដោកធ្វើពីឈើកាប់ពីដើម Tung
ត្រដោកធ្វើពីឈើកាប់ពីដើម Blaang
ត្រដោកធ្វើពីឈើកាប់ពីដើម Lat ដែលឮល្អ
មានរបស់អស្ចារ្យ មានទាំងអស់ មានរបស់នេះ មានរបស់នោះ
ភូមិជាំងពិតជាអស្ចារ្យ

នៅភូមិត្រាង គេឮសំឡេង
សំឡេងស្លឹកចេក
សំឡេងស្លឹកអម្ពិល ពិតជាអស្ចារ្យ
សំឡេងដើមអម្ពិល Reh សំឡេងផ្តៅជាំង ពិតជាអស្ចារ្យ
សំឡេងស្បូវ Laac ដើមស្បូវ Laac ប្រភេទ jaa ពិតជាអស្ចារ្យ
សំឡេងដើមស្បូវ Laac យោលយោក គំនរដើមស្បូវ Laac
សំឡេងហ្វូងមនុស្សនៅមួយកន្លែង ឬនៅពាសពេញវាលស្រែ
សំឡេងហ្វូងមនុស្សសម្រុកចូលក្នុងផ្ទះ
មនុស្សម្នាចំនួនសាមសិបនាក់ពពាក់ពពូនគ្នាពេញផ្ទះធំ
មានអ្វីគ្រប់យ៉ាងដែលគេចង់បាន មែនហើយ នៅភូមិជាំង
នៅក្នុងភូមិជាំង កូនប្រុស Rong អូហ៍ មានទ្រព្យសម្បត្តិគ្រប់យ៉ាង ម្ចាស់ស្រុកៈ
ឃ្មោះរាងស្លឹក Traang ជ្រុងសំប៉ែត
គងរាងស្លឹក Traang ជ្រុងសំប៉ែត
ឃ្មោះញ៉រដោយឯកឯង អ្នកវាំចាក់ក្បាច់នៅនឹងកន្លែង
ពាងប្រភេទ Gri មានឆ្លាក់ក្បាច់បញ្ឆិត នៅក្នុងភូមិជាំង កូនប្រុស Rong ក៏មាន
ពាង Gri ត្រចៀកបី នៅក្នុងភូមិជាំង កូនប្រុស Rong ក៏មាន
ពាងប្រភេទ Rêêt ពាងប្រភេទ Rêêt ចំនួនសាមសិប
ឆ្នាំងបាយ អង្ករសម្រាប់មួយរយគ្រួសារក៏ដាក់មិនពេញឆ្នាំងផង
ពាង Rto ពួកគេយកចេញ ពាង Rtaang ពួកគេទុកនៅនឹងកន្លែង
មានសព្វគ្រប់ គេចង់បានអីក៏មានដែរនៅភូមិជាំង...

## ១.៣. ផ្ទះនៅក្នុងភូមិ[៦] ( cuaːɲ taː ɓɔːn )



ផ្ទះទាបជាប់ដី (cuaːɲ) ɟɛj

[៦] អត្ថន័យនៃការប្រើប្រាស់លេខគឺដូចគ្នាទាំងអស់៖ លេខនីមួយៗត្រូវនឹងរូបភាពទៅតាមលំដាប់លំដោយ។ រូបរបស់ដែលយកមកបង្ហាញ និងការពិពណ៌នាទាំងឡាយធ្វើឡើងជាភាសាព្នង ដោយមានបកប្រែ។




ផ្ទះទាបមានដើមឈើ Bla:ŋ នៅក្បែរ[៧] (ɟej nha:n ma: tɜ:m bla:ŋ)




ផ្ទះខ្ពស់ « ទំនើប » (ɟej ɲih mhe:)

[៧] na:w tɜ:m bla:ŋ
ḅu: cʰrɛh rpu: tɜ:ç rhiaŋ ḅu: gɛh kɜ:p gɛh ḍu: rhiaŋ cʰah ɟih ḅu: gɛh na:w ɟa:n kual lah tɜ:ç rhiaŋ
ba: ma: rpu: ɟih ri: cʰɔʔ bo:k rpu: ntam ta: rgɔŋ ḅla:ŋ ɟih ri: tɜ:m bla:ŋ rɛh ɟe:ŋ kuɔŋ
ប្រវត្តិដើម Blaang
គេសម្លាប់ក្របីមួយក្បាលបើទទួលបានផលស្រូវ១០០កាផា។ បន្ទាប់ពីប្រមូលផលស្រូវរួច គេវាល់ស្រូវឃើញថាបាន១០០កាផា គេក៏ធ្វើពិធីបូជាមួយអោយឈ្មោះថា "ទទួលស្រូវបាន១០០កាផា ដោយបូជាក្របីមួយក្បាល"។ គេកាត់ក្បាលក្របីយកទៅព្យួរនៅលើកូនដើម Blaang ដើមនេះដុះឫស ហើយធំក្លាយជាដើមឈើ។

## ១.៤. ផ្ទះនៅលើគុម្ពោតព្រៃ (cuaːɲ taː miːr)





ផ្ទះខ្ពស់សម្រាប់ឃ្លាំមើល (cuaːɲ nkɜːp)





ផ្ទះនៅជាប់ដី (cuaːɲ taː nɛh)

# ២. លំនៅឋាន ខាងក្នុង វត្ថុមានតម្លៃ

រូបដែលយើងបង្ហាញជូនខាងក្រោមនេះ គឺជារូបរបស់របរដែលមាននៅខាងក្នុង chuaanh jey មានន័យថា ផ្ទះទាបបុរាណ។ ទំហំនិងការរៀបចំនៅខាងក្នុងអាចមានការប្រែប្រួល ប៉ុន្តែកន្លែងសំខាន់ៗ ដូចជាបន្ទប់ម្ចាស់ផ្ទះ ជង្រុកស្រូវ និងកន្លែងដាក់របស់មានតម្លៃ ដូចជា ពាង ឃ្មោះ និង kuat njoh ស្ថិតនៅកន្លែងដូចៗគ្នា។

## ២.១. ខាងក្នុង (taː troːm ɟɛj)





ជង្រុកស្រូវ កញ្ជេរដាក់ស្រូវ (ntur ḅaː, ḍrɔŋ ḅaː)



គ្រែ ជញ្ជាំងបន្ទប់ (grɛː, mpiːr ɟroːw)



ចង្ក្រាន (uɲ nak)



ចង្ក្រាន កន្លែងដាក់ទឹក (ឆ្នាំង ឃ្លោក...)
(uɲ nak, ḓrɛh ḓa:k)



ពាង កាផាwɛ:l (jaŋ cʰah wɛ:l)
កាផាប្រភេទខុសៗគ្នា (cʰah nḓra:ŋ, cʰah klɛh, cʰah ḓrɔ:k)



ចង្ក្រាន ថ្មចង្ក្រាន (uɲ nak, luʔ nak)
គ្រែ ជ្រុងគ្រែ រនាបទទឹង រនាបបណ្ដោយ (grɛ:, ḅɔ:ŋ grɛ:, rpaç grɛ:)



ចង្ក្រាន កៅអីទាប កាផាវាល់ស្រូវ (uɲ nak, rnɜ:l, cʰia:w)



ចង្ក្រាន ធ្នើរដាក់ទឹក (uɲ nak, rkɜl an ḓa:k) កន្ត្រកត្រី កូនចេក (nɜr gɜr ka:, ɟu: pri:t)
ពោតពូជ (mpɔ: nti:l) ចង្អេរ សសរ ធ្នឹមភ្ជាប់ពីដំបូលទៅជង្រុកស្រូវ (ḓo:ŋ, mɛh, nga:ŋ cua:ɲ)



ចង្ក្រាន ផ្ទើរ ចង្អេរ កាផាវាល់ស្រូវ
(uɲ nak, nd̤rɜːŋ, d̤oːŋ cʰiaːw)



ជង្រុកស្រូវ ធ្លាកណ្ដាលក្រោមជង្រុកស្រូវ ផ្ទើរខ្ពស់ ចំណង
(ntur b̤aː, ɲuaːŋ nɜːŋ, ŋleːŋ)



ពាង គ្រែ ជង្រុកស្រូវ (jaŋ, grɛː, ntur b̤aː)



ពាង កន្ត្រកដាក់ njoh (jaŋ, kuat njoh)



ពាង ខ្សែទាក់ដំរី (jaŋ, ḅrat kuac rwɛh)



បន្ទប់ ផ្លាកណ្ដាល ខ្សែចងជើងដំរី (ɟro:w, ɲua:ŋ, ŋle:ŋ)



ពាង (jaŋ)

## ២.១.១. វត្ថុមានតម្លៃនៅក្នុងផ្ទះ[៨] (nd̤ɜː klɛj taː troːm cuaːɲ)



ពីឆ្វេងទៅស្តាំ ពាង ពាងមានការតុបតែងលំអ (jaŋ rluːŋ, jaŋ nd̤raːŋ)

[៨] nd̤ɜː klɛj taː troːm cuaːɲ b̤uː nɔːŋ gɛh kɜːt aɜ kuat njoh, gun ŋlaːr, cɜŋ, gɔːŋ, jaŋ rluːŋ, rcʰɛː brat kuac rwɛh b̤riː
"វត្ថុមានតម្លៃនៅក្នុងផ្ទះជនជាតិព្នង មានដូចខាងក្រោម៖ kuat njoh ថ្មគ្រីស្តាល់ ឃ្មោះ គង ពាង rluung និងខ្សែទាក់ដំរី"



kuat njoh[៩]



ពាង និងឃ្មោះ (jaŋ nhaːɲ maː cɜŋ)



ឈ្មោះពាងប្រភេទផ្សេងៗគ្នា
(jaŋ ntaːŋ kɛh, jaŋ $c^{h}$uh (២) jaŋ nd̤raːŋ)



ឈ្មោះពាងប្រភេទផ្សេងៗគ្នា
(ɟaŋ rluːŋ, jaŋ moh, jaŋ krɛːŋ)

[៩] kuat njoh gɛh naːr iar rhɛː b̤aː kaːŋ $c^{h}$ur kaːŋ rpuː njoh b̤uː teʔ taː troːm cuaːɲ b̤oːŋ b̤ic joːr lah b̤uː oːp b̤rah wat b̤oːk nhaːw $c^{h}$ak gɛh maː b̤laːw waŋ kaː waŋ kaː-$c^{h}$aː gɛh nd̤roːk gɛh rpuː gɛhrwɛh
" kuat njoh រួមមានស្លាបមាន់ មាន់ឈ្មោលបូជា ចំបើង ចង្កាជ្រូក ឬក្របីបូជា និង njoh ។ គេដាក់វានៅក្នុងផ្ទះត្រង់កន្លែងម្ចាស់ផ្ទះគេង។ ដោយសាររបស់នេះ គេបន់ស្រន់ព្រះសូមអោយឆ្លាត មានកម្លាំងរកស៊ី និងរកបានទ្រព្យសម្បត្តិដូចជារកបាន គោ ក្របី ដំរី ជាដើម"។

## ២.២. ចំណុចលំអិតនៃការសាងសង់ផ្ទះទាប[១០] (nti:l nd̤ɜ: ɟa:n ɟɛj)



បង្គោលមានគន្លាក់នៅខាងចុង (mɛh b̤u: b̤a:k)



បង្គោលមានគន្លាក់នៅខាងក្បៀន ដើម្បីដាក់ធ្នឹម
(lo:k tro:m gɛj ma: rŋlap : nɟɔ:n)



ឈ្មោះកន្លែងផ្សេងៗនៃដំបូល
(ɟa: du peat, rna:ɲ rgap, $c^{h}$e:k ɟa:)

[១០] b̤u: peat ɟa: an gɛh d̤u: peat ja: ɲuaɲ gɛj ma: kat ngap mpaɲ an nɜp rɛh b̤u: pu:t paŋ an nɜp rla:w  ma: ɲuaɲ glɛ: plah ngap mpaɲ b̤u: kual lah ngap mpi:r ta:ɲ ma: ngɔŋ nha:ɲ rna:ɲ glɛ:

"គេក្រងស្បូវ ɟa: ដើម្បីធ្វើបន្ទប់ ɟa: ។ គេប្រើ ɲuaɲ ដើម្បីចង ngap អោយជាប់។ ផ្ដៅ nɛh គេចងផ្ដោបធ្វើអោយ ngap កាន់តែជាប់ថែមទៀត។ បន្ទះឬស្សីពុះហើយ glɛ: ឈ្មោះ "ngap" មានន័យថា ចំណង ដែលឈ្មោះនេះបានមកដោយសារវាចងរឹតបន្តឹង mpaɲ ។ នៅលើជញ្ជាំងឬស្សី glɛ: គេឃើញ ngɔŋ និង rna:ɲ glɛ: "



ផ្ទះកំពុងសាងសង់ (ɟɛj nto:l ma: ɟa:n)

## ៣. របស់របរ ឧបករណ៍ សិប្បកម្ម[១១]

វាជារឿងធម្មតាទេដែលគេសម្គាល់ឃើញរបស់របរនិងកិច្ចការសិប្បកម្មបញ្ជាក់ពីអត្តសញ្ញាណនៃវប្បធម៌មួយ។ របស់របរទាំងនោះត្រូវបានគេប្រើប្រាស់ដើម្បីកំណត់ការវិវត្តន៍ផ្នែកបច្ចេកទេសរបស់ជនជាតិមួយ។ យើងសូមបង្ហាញជូនក្នុងស្នាដៃនេះនូវរបស់របរនិងវត្ថុប្រពៃណីមួយចំនួន។ យើងនឹងពិពណ៌នាអោយបានលម្អិតនូវការងារតម្បាញនិងការងារធ្វើអំបោះ ដែលជាការងារប្រពៃណីពីររបស់ស្ត្រីតម្រូវអោយមានចំណេះធ្វើខ្ពស់។ ការងារធ្វើអំបោះហាក់ដូចជាបាត់បង់ទាំងស្រុងទៅហើយ គេក៏ភ្លេចរបៀបជ្រលក់ពណ៌តាមបែបបុរាណដែរ។ Khong ដែលយើងបានថតយកមកបង្ហាញនេះជារបស់ដែលគ្រួសារមួយចំនួនរក្សាទុកបានយ៉ាងខ្ជាប់ខ្ជួន។ តម្បាញដែលទើបចាប់មានសកម្មភាពឡើងវិញដោយសារអង្គការក្រៅរដ្ឋាភិបាលនានា ប្រព្រឹត្តទៅដោយប្រើអំបោះនាំចូល និងសម្រាប់ផលិតរបស់លក់អោយភ្ញៀវដែលឆ្លងកាត់សែនមនោរម្យតែប៉ុណ្ណោះ។



រទេះគោ (rnḍɛh nḍ̤ro:k)

[១១] អង្គការក្រៅរដ្ឋាភិបាលមួយឈ្មោះ Village Focus Cambodia ធ្វើការជាមួយសិប្បការិនីជនជាតិព្នង ជាពិសេស ស្ត្រីតម្បាញ តាំងពីឆ្នាំ២០០៥មក។ អង្គការនេះលក់ផលិតផលសិប្បកម្មជនជាតិព្នងនៅក្នុងខេត្តនេះ។ ប្រធានអង្គការ លោក Bill Herod បានប្រាប់ខ្ញុំថាលោកធ្វើការជាមួយសិប្បករព្នង ជាពិសេស ស្ត្រីតម្បាញ តាំងពីឆ្នាំ២០០៥មក។



ចង្ក្រានដំដែក (ntuk ḅuː ciar)





ស្នា (naː)



ចង្អេរ ព្រួញ (ḍoːŋ nhaːɲ har )



ផ្គាក់ម៉្យាង (tuç)



ពូថៅម៉្យាង (c$^{h}$u:ŋ)





ត្បាល់បុកបន្លែ កាំបិត ឃ្លោក
(rna:j ɟur tra:w, pɛç, no:ŋ)

កាផា និង ពូថៅ
(c$^{h}$ah nha:ɲ ma: c$^{h}$u:ŋ)



កណ្ដៀវច្រូតស្រូវ (ɲɛ:w rɛ:k ba:)



កូនកាំបិត ស្រោម (pɛç ɟeʔ, ndro:m pɛç)



កាំបិតម៉្យាង ផ្គាក់ ពូថៅដៃ (pɛç kut, tuç, pɛç t$^{h}$a:w)



កាផា ត្បាល់ ចបជីក ចបកាប់ (c$^{h}$ia:w, mpa:l, ka:w ci:k tuç)



កាផានៅក្នុងផ្ទះ (c$^{h}$ah ta: tro:m cua:ɲ)



កាផាម៉្យាង (c$^{h}$ah ɟuʔ)



សំបុកមាន់ (nta:t iar)



ទ្រូម៉្យាង (pa:m rḍa: a:ɲ)



សាក់កាដូចាក់ពីឫស្សី (rda: a:ɲ)



ទ្រូម៉្យាង ($c^h$rɔʔ)



ទ្រូម៉្យាង (ḍo:m)



សំណាញ់ និង ម្ជុលចាក់សំណាញ់ (ɟa:l weʔ kʰat ɟa:l)



ត្បាល់បុកគ្រឿង អង្រៃ (mpal ɟuh mrac rna:j)



អង្រៃបុកស្រូវ ឃ្លោកទឹក (rna:j peaŋ no:ŋ ḍa:k)



[១២]ឆ្នាំងចំហុយបាយដំណើប (nkul mʔe:t)

